# រឿងជោគជ័យក្រុងពោធិ៍សាត់



| | |
|---|---|
| ឈ្មោះកម្មវិធី | គម្រោង PROCEED |
| ចំណងជើងរឿង | **សកម្មភាពថ្មី ជោគជ័យថ្មី លើដែនដីចាស់** |
| កាលបរិច្ឆេទនៃការកត់ត្រា | ០៨ មីនា ២០១៥ |
| រឿងនោះកើតឡើងនៅពេលណា | ចាប់តាំងពីឆ្នាំ២០១៣ |
| ឈ្មោះភូមិ ឬស្រុក (ទីកន្លែងដែលរឿងបានកើតឡើង) | ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ឈ្មោះអ្នកនិយាយរឿងប្រាប់ | លោក **សំរិទ្ធិ អេង** ប្រធានក្រុមប្រឹក្សាក្រុងពោធិ៍សាត់ |
| -ចំនួនអ្នកទទួលផល (ជាក្រុម)ដែលទទួលផលពីសកម្មភាពរបស់ បុគ្គលដែលផ្តល់រឿង | (ប្រសិនបើមាន) |
| -អាយុជាមធ្យម (បុរស ឬស្ត្រី) | ៦៣ ឆ្នាំ |
| អ្នកសម្ភាសន៍(តួនាទី, អង្គភាព) | ហួន វិទ្យា មន្ត្រីកម្មវិធី អង្គការអនាគតកុមារ |
| **អ្នកកត់ត្រា(តួនាទី, អង្គភាព)** | ឡុញ សុខឿន មន្ត្រីសម្របសម្រួល អង្គការអនាគតកុមារ |

## <u>ពិពណ៌នារឿង</u>

ពោធិ៍សាត់ គឺជាក្រុងមួយ ក្នុងចំណោមក្រុង ស្រុក ៨ផ្សេងទៀត ក្នុងប្រទេសកម្ពុជាដែលបានអនុវត្តគម្រោងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (PROCEED) សម្របសម្រួលដោយអង្គការអនាគតកុមារ ឧបត្ថមមូលនិធិ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍរបស់ប្រទេសស៊ុយអែត តាមរយៈអង្គការផេកកម្ពុជា។

លោក **សំរិទ្ធិ អេង** អាយុ៦៣ឆ្នាំ បច្ចុប្បន្ន ជាប្រធានក្រុមប្រឹក្សា ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ លោក គឺជាថ្នាក់ដឹកនាំដែលបានទទួលការគោរពរាប់អានពីក្រុមការងារ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។ លោក មានភាពស្និតស្នាល និងទំនាក់ទំនងល្អក្នុងភាពជាដៃគូជាមួយអង្គភាព និងអង្គការផ្សេងដែលកំពុងអនុវត្តការងារក្នុងក្រុងពោធិ៍សាត់។ ជាមួយគ្នានេះដែរ លោក និងសមាជិកក្រុមប្រឹក្សាក្រុងបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពគម្រោង PROCEED និងបានចុះអនុសារណៈយោគយល់ជាមួយអង្គការអនាគតកុមារ នៅថ្ងៃទី ១២ ខែកម្ភៈ ឆ្នាំ ២០១៣។

ក្នុងភាពជាដៃគូ **លោក សំរិទ្ធិ អេង** បានចូលរួមវគ្គបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ និងចូលរួមទស្សនកិច្ចសិក្សា ដកស្រង់បទពិសោធន៍ពីការអនុវត្តសកម្មភាពការងារតាមបណ្តាខេត្តផ្សេងៗជាច្រើន។ លោកបានអភិវឌ្ឍផ្នែកចំណេះដឹងយ៉ាងរហ័ស និងយល់ដឹងស៊ីជំរៅ ពីតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា កិច្ចតែងការ និងបែបបទនៃការរៀបចំវេទិកា។ សកម្មភាពជាច្រើនដែលលោកបានដឹកនាំមានដូចជា៖ កិច្ចប្រជុំអាណត្តិប្រចាំខែរបស់ក្រុមប្រឹក្សាក្រុងពោធិ៍សាត់ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ម៉ោងជួបប្រជាពលរដ្ឋ យុទ្ធនាការផ្សព្វផ្សាយផ្សេងៗ។ លោកក៏បានធ្វើជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ “ចូលរួមដើម្បីការឆ្លើយតប” របស់វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM 102MHz ដែលកម្មវិធីនេះបង្កើតឡើងដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបានចូលរួមលើកមតិយោបល់ បញ្ហា តម្រូវការផ្សេងៗ ទៅកាន់ក្រុមប្រឹក្សា និងអាជ្ញាធរពាក់ព័ន្ធធ្វើការបកស្រាយ និងឆ្លើយតប។

ក្រោយពីទទួលបានការបង្ហាត់បង្ហាញ និងបណ្តុះបណ្តាលអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យពីគម្រោង និងការយកចិត្តទុកដាក់អភិវឌ្ឍមូលដ្ឋានឱ្យរីកចម្រើនផង លោក សំរិទ្ធិ អេង និងសមាជិកក្រុមប្រឹក្សាក្រុងពោធិ៍សាត់ មានភាពបើកចំហជាងមុន ហើយចូលរួមជជែកពិភាក្សារកដំណោះស្រាយជូនប្រជាពលរដ្ឋយ៉ាងផុសផុល មានតម្លាភាព គណនេយ្យភាព និងមានគំនិតច្នៃប្រឌិតក្នុងការអនុវត្តការងារ។ ជាក់ស្តែង កិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សាក្រុង គឺធ្វើឆ្លាស់គ្នា ម្តងរៀបចំធ្វើនៅសាលាក្រុង ឯខែបន្ទាប់ធ្វើនៅសង្កាត់ ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងជនងាយរងគ្រោះហ៊ានចូលរួម និងហ៊ានលើកបញ្ហា។ ជាមួយនឹងការផ្លាស់ប្តូរនេះ លោក សំរិទ្ធិ អេង បានមានប្រសាសន៍ថា “ខ្ញុំប្រកាន់យកនៅគោលការណ៍ចំនួនបី គឺ **ចង់ អាច និងហ៊ានចូលរួម**។ នៅពេលមានវេទិកាម្តងៗ ខ្ញុំតែងតែបានបង្កភាពស្និតស្នាលជាមួយប្រជាពលរដ្ឋ និងប្រាប់អំពីផលប្រយោជន៍ និងតម្លៃនៃការចូលរួមជាមួយក្រុមប្រឹក្សាជាមុន។ ពីដំបូងឡើយប្រជាពលរដ្ឋមិនសូវមានការចូលរួមច្រើននោះទេ ជា

ពិសេសក្រុមជនងាយរងគ្រោះ ។ **លោក សំរិទ្ធិ អេង** បានបញ្ជាក់ទៀតថា អង្គការសហគមន៍មូលដ្ឋាន (CBO) មានតួនាទីយ៉ាងសំខាន់ ជាអ្នកពាំនាំព័ត៌មានពីក្រុមប្រឹក្សាមកប្រាប់ប្រជាពលរដ្ឋ និងនាំបញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋដល់ក្រុមប្រឹក្សាវិញ និងបានបង្ហាត់បង្ហាញប្រជាពលរដ្ឋឱ្យយល់ដឹងអំពីសិទ្ធិ តួនាទីរបស់ខ្លួន និងរបស់ក្រុមប្រឹក្សា ។

ចាប់តាំងពីពេលនោះមក ការចូលរួមរបស់ប្រជាពលរដ្ឋមានការកើនឡើង ប្រជាពលរដ្ឋមានភាពក្លាហានក្នុងការឡើងសួរ និងផុសផុលក្នុងការលើកបញ្ហារបស់ខ្លួន និងសហគមន៍ទៅកាន់ក្រុមប្រឹក្សាដើម្បីធ្វើការដោះស្រាយ ។ ជាក់ស្តែង (**<u>បញ្ហាទី១)</u>** ប្រជាពលរដ្ឋស្ទើរគ្រប់សង្កាត់ក្នុងក្រុងពោធិ៍សាត់ បានលើកពីបញ្ហាអគ្គិសនី (កុងទ័រភ្លើងដើរលឿនខុសប្រក្រតី) ។ ជាលទ្ធផលក្រុមប្រឹក្សាក្រុង បានអញ្ជើញវាគ្មិនមកពីអង្គភាពអគ្គិសនីផ្ទាល់ដើម្បីធ្វើការឆ្លើយតប និងពន្យល់ពីលក្ខណៈបច្ចេកទេស និងរបៀបនៃការប្រើប្រាស់ផ្សេងៗ ។ដើម្បីជាទំនុកចិត្ត ក្រុមហ៊ុនផ្តល់សិទ្ធិជូនប្រជាពលរដ្ឋដែលមានចម្ងល់ ឬមិនមានទំនុកចិត្តចំពោះក្រុមហ៊ុន អាចយកកុងទ័រភ្លើងនោះទៅដូរថ្មី ឬយកកុងទ័រចាស់នោះទៅធ្វើការវាស់វែងនៅក្រុមហ៊ុនផ្សេងបាន ។ **<u>បញ្ហាទី២</u>** ប្រជាពលរដ្ឋនៅភូមិកែវមុន្នី សង្កាត់បន្ទាយដី បានលើកឡើងបញ្ហា អនាម័យ គឺក្លិនលាមកស្អុយចេញពីក្រុមហ៊ុនចិញ្ចឹមសត្វស្វា ។ ក្រុមប្រឹក្សាក្រុងបានពិគ្រោះយោបល់គ្នា និងរកវិធីសាស្ត្រក្នុងការដោះស្រាយ ដោយគណៈអភិបាលបានកោះអញ្ជើញភាគីក្រុមហ៊ុន និងមន្ទីរបរិស្ថានទៅសិក្សាលក្ខណៈបច្ចេកទេស ។ ជាលទ្ធផលខាងក្រុមហ៊ុនបានសាងសង់ទៅតាមលក្ខណៈបច្ចេកទេស និងគោរពទៅតាមការណែនាំរបស់គណៈអភិបាល ។ ប្រជាពលរដ្ឋមានការសារទរ ចំពោះចំណាត់ការរបស់ក្រុង ។ **<u>បញ្ហាទី៣</u>** ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន ការបិទផ្លូវ បញ្ហាព្រំដី ការលក់ដូរដីធ្លី គ្រឿងញៀន បរិស្ថាន បញ្ហាបញ្ជីអត្រានុកូលដ្ឋាន (កើត,អាពាហ៍ពិពាហ៍,មរណៈភាព) ហើយបញ្ហាទាំងនេះ គ្រប់វេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ ថ្នាក់សង្កាត់/ក្រុង គឺលោកបានអញ្ជើញមន្ត្រីពាក់ព័ន្ធ មន្ទីរជំនាញ មកចូលរួមដូចជា អធិការក្រុង មេប៉ុស្តិ៍ ការិយាល័យអប់រំ នាយកសាលា មន្ទីររ៉ែ និងថាមពល សុរិយោដី ។ល។ ដូច្នេះប្រជាពលរដ្ឋមានភាពកក់ក្តៅ និងរីករាយក្នុងការចូលរួម លើកបញ្ហា និងទទួលយកដំណោះស្រាយ ។

ដោយសារការខិតខំប្រឹងប្រែងបំពេញការងាររបស់**លោក សំរិទ្ធិ អេង** ក៏ដូចជាសមាជិកក្រុមប្រឹក្សាក្រុង ទើបធ្វើមន្ត្រីក្រោមឱវាទ អង្គការដៃគូ ប្រជាពលរដ្ឋទទួលស្គាល់ លោក **សំរិទ្ធិ អេង** ថាជាថ្នាក់ដឹកនាំគំរូ មិនអាចខ្វះបានក្នុងការកសាង និងអភិវឌ្ឍន៍ក្រុងពោធិ៍សាត់ និងធ្វើឱ្យគម្រោងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (PROCEED)ទទួលបានជោគជ័យ ។

**ការអង្កេតលើចំនុចសំខាន់ៗ ៖ កាយវិការ អារម្មណ៍ អត្តចរិតរបស់អ្នកទទួលសម្ភាសន៍ លោក សំរិទ្ធិ អេង មានទំនុកចិត្តខ្ពស់លើខ្លួនឯងក្នុងការផ្តល់បទសម្ភាសន៍ ភាពស្រស់ស្រាយ ពន្យល់យឺតៗ និងច្បាស់លាស់ពីសកម្មភាពនីមួយៗ និងពេញចិត្តនិងឆ្លើយតប ព្រមទាំងចែករំលែក នូវបទពិសោធន៍ល្អៗជាច្រើនទៀត ។**

ផ្នែកផ្លាស់ប្តូរ **(Domain of changes)**

អភិបាលកិច្ចល្អ